# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ១៥១ គ.ជ.ប.ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈលេខាធិការកត់ត្រា នៃកិច្ចប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញសេចក្តីសម្រេចលេខ ០៤៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧។

## សម្រេច

### ប្រការ១.-

ត្រូវបានបង្កើតគណៈលេខាធិការកត់ត្រានៃកិច្ចប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- | អគ្គលេខាធិការ | | ប្រធាន |
| ២- | អគ្គលេខាធិការរង | | អនុប្រធាន |
| ៣- | លោក **ឌី តីរុណា** | អនុប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ៤- | លោក **គាព ទិចិត្រ** | អនុប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន | សមាជិក |

ប្រធានគណៈលេខាធិការកត់ត្រាមានសិទ្ធិចាត់ចែង និងជ្រើសរើសមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ដើម្បីជួយការងាររបស់គណៈលេខាធិការកត់ត្រា។

**ប្រការ២.–**

គណៈលេខាធិការកត់ត្រានេះ មានភារកិច្ចដូចតទៅ៖

- ស្រង់វត្តមានសមាជិក សមាជិកា គ.ជ.ប ចូលរួមក្នុងការប្រជុំ គ.ជ.ប
- ស្រង់វត្តមានសមាជិកផ្សេងទៀតដែលចូលរួមប្រជុំ
- ត្រួតពិនិត្យមើលថា គ្មានមនុស្សដទៃដែលមិនមែនជាសមាជិក សមាជិកា គ.ជ.ប នៅក្នុងកិច្ចប្រជុំសម្ងាត់របស់ គ.ជ.ប
- រាយការណ៍ជូនប្រធានអង្គប្រជុំពីវត្តមានអ្នកចូលរួមប្រជុំ
- រៀបចំការអនុម័តដោយលើកដៃ ឬការបោះឆ្នោតជាសម្ងាត់ តាមការសម្រេចរបស់ប្រធានអង្គប្រជុំ
- រាយការណ៍ជូនប្រធានអង្គប្រជុំ គ.ជ.ប អំពីចំនួនសមាជិក សមាជិកា គ.ជ.ប ដែលបានលើកដៃអនុម័ត
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃអង្គប្រជុំ គ.ជ.ប ដាក់ជូន គ.ជ.ប មុនបញ្ចប់កិច្ចប្រជុំ
- ធ្វើសេចក្តីព្រាងកំណត់ហេតុអង្គប្រជុំ គ.ជ.ប ដាក់ជូនអង្គប្រជុំ គ.ជ.ប លើកក្រោយពិនិត្យ អនុម័ត
- ថតចម្លងកំណត់ហេតុអង្គប្រជុំ គ.ជ.ប ចែកជូនសមាជិក សមាជិកា គ.ជ.ប និងអគ្គលេខាធិការដ្ឋាន គ.ជ.ប យ៉ាងយូរ៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃប្រជុំអនុម័ត
- រក្សាទុកកំណត់ហេតុអង្គប្រជុំ គ.ជ.ប ក្នុងកន្លែងដែលមានសុវត្ថិភាព
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឱ្យ។

**ប្រការ៣.–**

អគ្គលេខាធិការដ្ឋាន គ.ជ.ប និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៧

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក

**កន្លែងទទួល៖**

- សមាជិក សមាជិកា គ.ជ.ប
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៣
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ